# សោមនស្សជាតក



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធទេវទត្ត ដែលព្យាយាមធ្វើឃាតព្រះអង្គ បានត្រាស់ព្រះជាតកនេះមានពាក្យថា* **កោ តំ ហឹសតិ ហេឋេតិ** *ដូច្នេះជាដើម ។*

*គ្រានោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមសម្លាប់តថាគតដែរ រួចហើយទ្រង់នាំអតីតនិទានមកថា*

*ក្នុងអតីតកាល ព្រះរាជាព្រះនាម **រេណុ** សោយរាជសម្បត្តិ ក្នុងឧត្តរបញ្ចាលនគរ ដែលកុរុរដ្ឋ ។ គ្រានោះ តាបសឈ្មោះ* **មហារក្ខិតៈ** *មានតាបស ៥០០ ជាបរិវារ រស់នៅព្រៃហិមពាន្តអស់កាលដ៏យូរហើយ លោកនាំបរិវារត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ការសេពរសប្រៃ និងជូរ ក៏មកដល់ឧត្តរបញ្ចាលនគរ ហើយនៅក្នុងរាជឧទ្យាន លោកនិងបរិវារ*

ត្រាច់បិណ្ឌបាត្រ រហូតដល់រាជទ្វារ ។ ព្រះរាជាឃើញពួកឥសី ទ្រង់ជ្រះថ្លាក្នុងឥរិយាបថ ត្រាស់និមន្តពួកឥសីឲ្យអង្គុយក្នុងមហាពេងដែលតាក់តែងហើយ និងអង្គាសដោយអាហារដ៏ប្រណីត រួចត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តនៅក្នុងឧទ្យានរបស់ខ្ញុំ អស់វស្សានរដូវនេះចុះ ដូច្នេះហើយ ទ្រង់យាងទៅឧទ្យានជាមួយនឹងតាបស ឲ្យគេកសាងលំនៅ ថ្វាយបរិក្ខារសម្រាប់បព្វជិត ថ្វាយបង្គំ រួចទើបចេញទៅ ។

ចាប់ពីពេលនោះមក តាបសទាំងអស់នោះ តែងតែមកឆាន់ក្នុងរាជនិវេសន៍ ។ ចំណែកព្រះរាជាទ្រង់មិនមានបុត្រ ទោះជាព្រះអង្គធ្វើសេចក្ដីប្រាថ្នាបុត្រ ក៏មិនមានទាន់បុត្រមកកើតដែរ ។ កាលវស្សានរដូវកន្លងទៅ មហារក្ខិតតាបសចម្រើនពរលាព្រះរាជាថា ឥឡូវនេះ ព្រៃហិមពាន្តគួរជាទីរីករាយវិញហើយ ពួកអាត្មានឹងទៅទីនោះ ពោលយ៉ាងនេះហើយព្រះតាបសធ្វើសេចក្ដីពប់អាន ដោយសក្ការៈដែលគប្បីធ្វើហើយ ក៏ចេញទៅ, ក្នុងរវាងផ្លូវកាលឈានចុះកាន់ផ្លូវក្នុងមជ្ឈន្តិកសម័យ លោកនាំបរិវារទៅអង្គុយសម្រាកលើស្មៅខ្ចី នៅក្រោមដើមឈើ ដែលមានម្លប់ត្រជាក់មួយដើម ។

តាបសទាំងឡាយញុំាំងកថាឲ្យតាំងឡើងថា ព្រះរាជបុត្រដែលជាអ្នករក្សាវង្សត្រកូលមិនមានក្នុងព្រះរាជវាំងសោះ ប្រសិនបើព្រះរាជាបានបុត្រ ជាការប្រពៃណាស់ បវេណីនឹងបន្តទៅ ។ មហារក្ខិតតាបសស្ដាប់ពាក្យរបស់ពួកតាបសហើយ គិតថា តើបុត្រនឹងមានដល់ព្រះរាជា ឬមិនមានហ្ន៎ ? កាលពិចារណាហើយ ក៏ដឹងថា ទ្រង់នឹងមានបុត្រ ហើយពោលយ៉ាងនេះថា នែអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកកុំគិតច្រើនឡើយ ថ្ងៃនេះ ក្នុងវេលាបច្ចូសសម័យ មានទេវបុត្រមួយអង្គចុតិហើយ នឹងកាន់យកបដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសីរបស់ព្រះរាជា ។

មានជដិលកោងមួយរូបស្ដាប់ពាក្យនោះហើយ គិតថា ឥឡូវនេះ យើងនឹងបានជា**រាជកុលូបកៈ** (អ្នកចូលទៅកាន់រាជត្រកូល) គិតយ៉ាងនេះហើយ កាលតាបសទាំងឡាយធ្វើដំណើរទៅ ក៏ដេកធ្វើពុតជាឈឺ កាលពួកតាបសពោលថា អ្នកចូរមក ពួកយើងនឹងទៅ លោក៏

ពោលថា ខ្ញុំមិនអាចទៅទេ ។ មហារក្ខិតតាបសដឹងហេតុនៃការដេក របស់ជដិលកោងនោះ ហើយពោលថា លោកអាចទៅក្នុងកាលណា ចូរមកក្នុងកាលនោះចុះ រួចក៏នាំពួកឥសី ទៅកាន់ព្រៃហិមពាន្ត ។ ចំណែក**កុហកតាបស**ត្រឡប់ទៅវិញដោយរហ័ស ហើយឋិតនៅជិតរាជទ្វារ និងប្រាប់រាជបុរសឲ្យទូលព្រះរាជាថា តាបសដែលជាឧបដ្ឋាករបស់មហារក្ខិតៈនិមន្តមក កាលព្រះរាជាត្រាស់និមន្តឲ្យឡើងលើប្រាសាទ និងអង្គុយលើអាសនៈ ដែលគេរៀបចំប្រគេន។

ព្រះរាជាថ្វាយបង្គំកុហកតាបស ស្តេចប្រថាប់ក្នុងទីដ៏សមគួរ ត្រាស់សួរដល់ការមិនមានរោគរបស់ពួកឥសី ហើយត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រឡប់និមន្តមកលឿនម្ល៉េះ លោកម្ចាស់និមន្តមកដោយរហ័សនេះ ព្រោះប្រយោជន៍អ្វី ?

**កុហកតាបសពោលថា** បពិត្រមហារាជ ពិតមែនហើយ កាលពួកអាត្មាធ្វើដំណើរទៅ ពួកឥសីអង្គុយសម្រាកជាសុខ (ក្នុងរវាងផ្លូវ) បាននិយាយគ្នាថា ប្រសិនបើបុត្រដែលជាអ្នករក្សាបវេណីគប្បីកើតដល់ព្រះរាជា ជាការល្អណាស់ អាត្មាស្តាប់ពាក្យនោះហើយ ក៏ពិចារណាដោយទិព្វចក្ខុថា បុត្រនឹងមានដល់ព្រះរាជាឬមិនមាន កាលពិចារណាហើយ បានឃើញថា ទេវបុត្រដែលមានឫទ្ធិច្រើនចុតិហើយកើតក្នុងផ្ទៃព្រះអគ្គមហេសីសុជម្មា អាត្មាមកដើម្បីប្រាប់ព្រះអង្គថា ព្រះនាងកាលមិនដឹង នឹងញ៉ាំងគភ៌ឲ្យវិនាស បពិត្រមហារាជ អាត្មាប្រាប់ព្រះអង្គហើយ នឹងទៅ ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាសកុំទៅ ។ ទ្រង់មានចិត្តរីករាយជ្រះថ្លា នាំកុហកតាបសទៅកាន់ឧទ្យាន រៀបចំចាត់ចែងទីលំនៅថ្វាយ ។ ចាប់ពីពេលនោះមក តាបសនោះតែងមកឆាន់ក្នុងរាជត្រកូល ហើយរស់នៅក្នុងទីនោះឯង លោកក៏មានឈ្មោះថា **ទិព្វចក្ខុកៈ** ។

គ្រានោះ ព្រះពោធិសត្វចុតិចាកភពតាវត្តិង្ស ហើយកាន់យកបដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសីនោះ ។ កាលលោកប្រសូតហើយ ក្នុងថ្ងៃថ្វាយព្រះនាម ពួកញាតិធ្វើព្រះនាមថ្វាយលោកថា **សោមនស្សកុមារ** ។ ព្រះពោធិសត្វចម្រើនឡើងដោយការរក្សាជាព្រះកុមារ ។

ចំណែកកុហកតាបសដាំគ្រឿងទេសផ្សេងៗ បន្លែ និងវល្លិដែលមានផ្លែ ក្នុងទីចំណែកមួយនៃឧទ្យាន ហើយលក់ដូរបន្លែ សន្សំទ្រព្យ ។ កាលព្រះពោធិសត្វមានអាយុ ៧ ឆ្នាំ បច្ចន្តជនបទរបស់ព្រះរាជាមានការបះបោរ ។ ព្រះរាជាត្រាស់នឹងបុត្រថា សូមអ្នកកុំប្រមាទទិព្វចក្ខុតាបស ទ្រង់ឲ្យព្រះរាជកុមារទទួលហើយ ស្តេចយាងទៅដោយត្រាស់ថា យើងនឹងរម្ងាប់បច្ចន្តជនបទ ។

ថ្ងៃមួយ ព្រះកុមារគិតថា យើងនឹងមើលជដិល គិតហើយក៏យាងទៅឧទ្យាន បានឃើញជដិលកោងដែលស្លៀកសំពត់មានលេវមួយផ្ទាំង ដណ្តប់មួយផ្ទាំង ដៃទាំងពីរកាន់ក្អមទឹក ស្រោចបន្លែ ទើបដឹងថា តាបសនេះជាជដិលកោង មិនធ្វើសមណធម៌របស់ខ្លួនទេ បែរជាទៅធ្វើ**បណ្ណិកកម្ម** ដូច្នេះហើយ លោកធ្វើតាបសនោះឲ្យអៀនខ្មាស ដោយពោលថា នៃគហបតីជំនួញ លោកធ្វើអ្វី ថារួចហើយ ព្រះកុមារមិនថ្វាយបង្គំ ក៏ចេញទៅ ។

ជដិលកោងគិតថា ឥឡូវនេះ ព្រះរាជកុមារនេះជាសត្រូវ (របស់យើង) អ្នកណានឹងដឹងថា កុមារនេះធ្វើអ្វី យើងគួរនឹងញុំាងកុមារនេះឲ្យវិនាសឥឡូវនេះ ។ កាលព្រះរាជាយាងមកវិញ ជដិលកោងគប់គ្រវែងដុំថ្ម វាយបំបែកផ្ទាំងទឹក រោយរាយបាចសាចស្មៅលើបណ្ណសាលា លាបសរីរៈដោយប្រេង ចូលទៅក្នុងបណ្ណសាលា ដណ្តប់ទាំងក្បាល ដេកលើគ្រែ ធ្វើដូចជាមានសេចក្តីទុក្ខខ្លាំង ។

ព្រះរាជាយាងមក ទ្រង់ប្រទក្សិណនគរហើយ ព្រះអង្គមិនទាន់ចូលរាជនិវេសន៍ ស្តេចគិតថា យើងនឹងឃើញទិព្វចក្ខុតាបសរបស់យើងសិន ដូច្នេះទើបយាងទៅទ្វារបណ្ណសាលា

*ឃើញបណ្ណសាលាមានសភាពផ្សេងៗ គិតថា មានរឿងអ្វី ស្ដេចចូលទៅ ឃើញតាបសកំពុងដេក ទ្រង់ប្រឫបាច់ជើង ហើយត្រាស់គាថាទី ១ ថា*

**កោ តំ ហិំសតិ ហេឋេតិ, កិំ ទុម្មនោ សោចសិ អប្បតីតោ;**
**កស្សជ្ជ មាតាបិតរោ រុទន្តុ, ក្វជ្ជ សេតុ និហតោ បថព្យា។**

*នរណាប្រហារលោក ជេរលោក ម្ដេចក៏លោកអាក់អន់ចិត្ត មិនត្រេកអរ សោកសង្រេងម្ល៉េះ ថ្ងៃនេះ ចង់មាតាបិតារបស់នរណារទួញយំ ថ្ងៃនេះ ចង់នរណាត្រូវគេបៀតបៀនដេកលើផែនដី (ក៏លោកមិនត្រូវជាអុកជាទុក្ខទេ) ។*

*ជដិលកោងស្ដាប់ពាក្យនោះហើយ ដកដង្ហើមធំ ក្រោកឡើង ពោលគាថាទី ២ ថា*

**តុដ្ឋាស្មិ ទេវ តវ ទស្សនេន, ចិរស្សំ បស្សាមិ តំ ភូមិបាល;**
**អហិំសកោ រេណុមនុប្បវិស្ស, បុត្តេន តេ ហេឋយិតោស្មិ ទេវ។**

*បពិត្រព្រះសម្មតិទេព អាត្មាភាពត្រេកអរ ដោយការបានឃើញនូវព្រះអង្គ បពិត្រភូមិបាល អាត្មាភាពឃើញព្រះអង្គយូរហើយ បពិត្រព្រះសម្មតិទេព ព្រះនាមរេណុ អាត្មាភាពមិនមែនជាអ្នកបៀតបៀនទេ ប៉ុន្តែអាត្មាភាពត្រូវព្រះរាជបុត្រ របស់ព្រះអង្គចូលមកបៀតបៀនហើយ ។*

*បន្ទាប់ពីនេះទៅ ជា***ឧត្តានសម្ពន្ធគាថា** *ដែលគប្បីជ្រាបតាមន័យព្រះបាលីថា*

**អាយន្តុ នោវារិកា ខគ្គពន្ធា, កាសាវិយា យន្តុ អន្តេបុរន្តំ;**
**ហន្ត្វាន តំ សោមទត្តំ កុមារំ, ឆេត្វាន សីសំ វរមាហរន្តុ។**

(ព្រះបាទរេណុក្រោធហើយត្រាស់ថា) ពួកអ្នកចាំទ្វារ មានព្រះខ័នកាន់ហើយ ពួកពេជ្ឈឃាដចូរមក ចូរទៅខាងក្នុងបុរី ចូរសម្លាប់សោមនស្សកុមារនោះ កាត់ក្បាលដ៏ប្រសើរ នាំមកឲ្យអញ ។

បេសិតា រាជិនោ ទូតា, កុមារំ ឯតទព្រវុំ;
ឥស្សរេន វិតិណ្ណោសិ, វធំ បត្តោសិ ខត្តិយ។

ពួករាជទូត ដែលព្រះរាជា ទ្រង់បញ្ជូនទៅហើយ បាននិយាយនឹងព្រះរាជកុមារ យ៉ាងនេះថា បពិត្រក្សត្រ ព្រះអង្គទ្រង់ធ្លងផុតចាកឥស្សរភាពហើយ ព្រះអង្គដល់នូវសេចក្ដីស្លាប់ហើយ ។

ស រាជបុត្តោ បរិទេវយន្តោ, ទសង្គុលឹ អញ្ជលឹ បគ្គហេត្វា;
អហម្បិ ឥច្ឆាមិ ជនិន្ទ ទដ្ឋុំ, ជីវំ មំ នេត្វា បដិទស្សយេថ។

ព្រះរាជបុត្រនោះ ក៏ទ្រង់បរិទេវនាការ ផ្គងក្រពុំម្រាមព្រះហស្តទាំង ១០ ថា បពិត្រព្រះអង្គជាធំជាងជន ចំណែកទូលព្រះបង្គំជាខ្ញុំ ចង់ឃើញព្រះអង្គ អ្នកទាំងឡាយចូរនាំយើងទាំងរស់ទៅក្រាបបង្គំថ្វាយ (ដល់ព្រះមហាក្សត្រ) ។

តស្ស តំ វចនំ សុត្វា, រញ្ញោ បុត្តំ អទស្សយុំ;
បុត្តោ ច បិតរំ ទិស្វា, ទូរតោវជ្ឈភាសថ។

ពួករាជទូតបានស្ដាប់វាចារបស់ព្រះរាជបុត្រនោះហើយ ក៏នាំព្រះរាជបុត្រ ទៅថ្វាយព្រះរាជា ចំណែកខាងព្រះរាជបុត្រ លុះបានឃើញព្រះរាជបិតាហើយ ក៏ក្រាបបង្គំទូលអំពីចម្ងាយថា

អាគច្ឆុំ ទោវារិកា ខគ្គពន្ធា, កាសាវិយា ហន្តុ មមំ ជនិន្ទ;
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ, អបរាធោ កោ និធ មមជ្ជ អត្ថិ។

*បពិត្រព្រះជនិន្ទ ពួកអ្នកចាំទ្វារ មានព្រះខ័នកាន់ហើយ ពួកពេជ្យឃាដមក ដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ ថ្ងៃនេះទូលព្រះបង្គំជាខ្ញុំ មានកំហុសដូចម្ដេចក្នុងរឿងនេះ ទូលព្រះបង្គំសួរហើយ សូមទ្រង់ប្រាប់សេចក្ដីនុ៎ះ ។*

*ពាក្យថា* **ស រាជបុត្តោ** *(ព្រះរាជបុត្រនោះ) សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រនោះ ស្ដាប់ពាក្យរាជទូតទាំងនោះហើយ ទ្រង់តក់ស្លុតចំពោះសេចក្ដីស្លាប់ ក្រោកចាកភ្លៅព្រះមាតា ។ ពាក្យថា* **តស្ស (របស់ព្រះរាជបុត្រនោះ)** *សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ពួកទូតស្ដាប់ពាក្យរបស់ព្រះរាជបុត្រនោះហើយ មិនហ៊ានសម្លាប់ គ្រាន់តែចាប់អូសទាញទៅដោយខ្សែ ដូចជាអូសគោ នាំយកទៅថ្វាយព្រះរាជា ។ កាលពួកពេជ្ឈឃាដកំពុងនាំព្រះរាជកុមារទៅ សូម្បីព្រះនាងសុធម្មាទេវី ពួកស្រីស្នំ មួយអន្លើដោយពួកទាសីជាបរិវារ និងអ្នកនគរនិយាយគ្នាថា ពួកយើងនឹងមិនឲ្យព្រះរាជាសម្លាប់ព្រះរាជកុមារ ដែលជាអ្នកមិនមានទោស ដូច្នេះទើបទៅជាមួយនឹងព្រះរាជកុមារ ។*

*ព្រះរាជាត្រាស់ថា* ***ភវត្តភព****ក៏នៅទាបជាង ទោសរបស់អ្នកធំណាស់ ដូច្នេះហើយ កាលនឹងពោលទោសរបស់ព្រះរាជកុមារ ទើបត្រាស់គាថាថា*

**សាយញ្ច ចាតោ ឧទកំ សជាតិ, អគ្គឹ សទា ចារិចរតប្បមត្តោ;**
**តំ តាទិសំ សំយតំ ព្រហ្មចារឹ, កស្មា តុវំ ព្រូសិ គហប្បតិ។**

***ទិព្វចក្ខុតាបស ជាអ្នកមិនធ្វេសប្រហែស ធ្វើការស្រោចទឹក បូជាភ្លើង រាល់ពេលល្ងាចព្រឹក ព្រោះហេតុអ្វី បានជាឯងហៅទិព្វចក្ខុតាបសនោះ ដែលជាអ្នកមានសេចក្ដីសង្រួម ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ មានសភាពដូច្នោះ ថាជាគហបតី ។***

*បន្ទាប់មក ព្រះរាជកុមារទូលថា បពិត្រព្រះសម្មតិទេព ទោសដូចម្ដេច របស់ទូលព្រះបង្គំដែលហៅគហបតីថា គហបតីនោះ ដូច្នេះហើយ ទើបត្រាស់គាថាថា*

**តាលា ច មូលា ច ផលា ច ទេវ, បរិគ្គហា វិរិជា សន្តិមស្ស;**
**តេ រក្ខតិ គោបយតប្បមត្តោ, តស្មា អហំ ព្រូមិ គហាប្បតិ។**

*បពិត្រព្រះសម្មតិទេព វត្ថុទាំងឡាយនៃកុលុបកៈនោះ មានច្រើនយ៉ាងណាស់ គឺផ្លែត្នោតផង ត្រាវនិងដំឡូងផង ផ្លែឈើទាំងឡាយផង កុលុបកតាបស របស់ព្រះអង្គនោះ ជាអ្នកមិនមានសេចក្តីធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវវត្ថុទាំងនោះ ព្រោះហេតុនោះ បានជាទូលបង្គំជាខ្ញុំហៅតាបសនោះថា គហបតី ។*

*បទថា* **មូលា** *បានដល់ មើមដំឡូងត្រាវជាដើម ។ បទថា* **ផលា** *បានដល់ ផ្លែរុក្ខជាតិវល្លិផ្សេងៗ ។ បទថា* **តេ រក្ខតិ គោបយតប្បមត្តោ (អ្នកមិនមានសេចក្តីធ្វេសប្រហែស)** *សេចក្តីថា តាបសដែលជាកុលូបកៈរបស់ព្រះអង្គនោះធ្វើ***បណ្ណិកកម្ម** *អង្គុយរក្សា ធ្វើរបងការពារ មិនមានការធ្វេសប្រហែស ដោយហេតុនោះ កុលូបកៈរបស់ព្រះអង្គ ទើបឈ្មោះថាគហបតិព្រាហ្មណ៍ ។*

*ព្រោះហេតុដូច្នេះ ទើបទូលព្រះបង្គំហៅតាបសនេះថា គហបតី ។ បើព្រះអង្គមិនជឿ ចូរហៅអ្នកលក់ដូរត្រង់ទ្វារទាំង ៤ មកសួរចុះ ។ ព្រះរាជាក៏ត្រាស់ហៅអ្នកទាំងនោះមកសួរ ។ អ្នកទាំងនោះទូលថា ពិតមែនហើយ ពួកទូលព្រះបង្គំបានទិញបន្លែ និងផលាផលពីដៃតាបសនេះ ។ ព្រះរាជកុមារត្រាស់ឲ្យពួករាជបុរសចូលទៅមើល***បណ្ណវត្ថុ** *។ រាជបុរសរបស់ព្រះកុមារក៏ចូលទៅក្នុងបណ្ណសាលា ហើយនាំយកបង្វេចគហាបណៈ និងមាសកៈ មកថ្វាយព្រះរាជា ។ ព្រះរាជាដឹងភាពជាអ្នកមិនមានទោសរបស់ព្រះមហាសត្វ ហើយត្រាស់គាថាថា*

**សច្ចំ ខោ ឯតំ វទេសិ កុមារ, បរិគ្គហា វិរិជា សន្តិមស្ស;**
**តេ រក្ខតិ គោបយតប្បមត្តោ, ស ព្រាហ្មណោ គហាបតិ តេន ហោតិ។**

*ម្នាលកុមារ អ្នកនិយាយពាក្យនេះពិតមែន របស់ទាំងឡាយនៃកុលុបកតាបសនោះ មានច្រើនយ៉ាង កុលុបកតាបសនោះ ជាអ្នកមិនធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវរបស់ទាំងនោះ ព្រោះហេតុនោះ ព្រាហ្មណ៍ក្លាយជាគហបតី ។*

*លំដាប់នោះ ព្រះមហាសត្វគិតថា ការដែលយើងចូលទៅព្រៃហិមពាន្តហើយបួសប្រសើរជាងនៅក្នុងសម្នាក់ព្រះរាជាពាលល្ងង់ខ្លៅបែបនេះ ព្រះអង្គធ្វើទោសរបស់ព្រះរាជាឲ្យប្រាកដជាក់ច្បាស់ក្នុងកណ្តាលបរិស័ទ ហើយទូលសូមលាថា ក្នុងថ្ងៃនេះ ទូលព្រះបង្គំនឹងចេញទៅបួស ។*

*ព្រះពោធិសត្វធ្វើនមស្ការបរិស័ទ ហើយពោលគាថាថា*

**សុណន្តុ មយ្ហំ បរិសា សមាគតា, សនេគមា ជានបទា ច សព្ពេ;**
**ពាលាយំ ពាលស្ស វចោ និសម្ម, អហេតុនា ឃាតយតេ មំ ជនិន្ទោ។**

*បរិស័ទព្រមទាំងអ្នកនិគម អ្នកជនបទ ដែលបានមកជួបជុំទាំងអស់គ្នា ចូរស្តាប់ពាក្យរបស់ខ្ញុំ ព្រះរាជានេះ ជាបុគ្គលពាល ស្តាប់តែពាក្យតាបសពាល ប្រើឲ្យគេសម្លាប់ខ្ញុំ ដោយការមិនសមហេតុ ។*

*ពាក្យថា* **ពាលាយំ ពាលស្ស** *(ព្រះរាជានេះ ជាបុគ្គលពាល ស្តាប់តែពាក្យតាបសពាល) សេចក្តីថា ព្រះរាជានេះជាបុគ្គលពាលដោយខ្លួនឯង ស្តាប់តែពាក្យជដិលកោងពាលនេះទៀត បញ្ជាឲ្យពេជ្ឈឃាដសម្លាប់ខ្ញុំ ដោយមិនសមហេតុ ។*

*ព្រះមហាពោធិសត្វពោលយ៉ាងនេះហើយ ថ្វាយបង្គំបិតា សូមព្រះរាជាអនុញ្ញាតឲ្យខ្លួនបួស ហើយពោលគាថាទៀតថា*

**ទឡ្ហស្មិំ មូលេ វិសដេ វិរូឡ្ហេ, ទុន្និក្ខយោ វេឡុ បសាខជាតោ;**
**វន្ទាមិ បាទានិ តវ ជនិន្ទ, អនុជាន មំ បព្ពជិស្សាមិ ទេវ។**

នាកាលឫសគល់ ចម្រើនមាំ ធំឡើង ឫស្សីដែលបែកមែកហើយ បុគ្គលមិនងាយនឹងគាស់ចេញទេ បពិត្រព្រះជនិន្ទ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះបាទាព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់អនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំសូមចេញបួស ។

តទៅនេះជាគាថាឆ្លើយឆ្លងរបស់ព្រះរាជា និងព្រះឱរសថា

(ព្រះរាជាត្រាស់ថា)

ភុញ្ជស្សុ ភោគេ វិបុលេ កុមារ, សព្ពញ្ច តេ ឥស្សរិយំ ទទាមិ;
អជ្ជេវ ត្វំ កុរុរដ្ឋំ ហោហិ រាជា, មា បព្ពជី បព្ពជ្ជា ហិ ទុក្ខា។

ម្នាលកុមារ អ្នកចូរបរិភោគនូវភោគៈទាំងឡាយដ៏ច្រើនចុះ បិតានឹងប្រគល់ឥស្សរិយយសទាំងអស់ដល់អ្នក អ្នកចូរសោយរាជ្យ ជាស្តេចរបស់អ្នកកុរុ ក្នុងថ្ងៃនេះឯង អ្នកកុំបួសឡើយ ត្បិតថា បព្វជ្ជាជាកិច្ចលំបាក់ណាស់ ។

(សោមនស្សកុមារទូលថា)

កិន្នូធ ទេវ តវមត្ថិ ភោគា, បុព្ពេវហំ ទេវលោកេ រមិស្សំ;
រូបេហិ សទ្ទេហិ អថោ រសេហិ, គន្ធេហិ ផស្សេហិ មនោរមេហិ។

បពិត្រព្រះសម្មតិទេព ភោគសម្បត្តិរបស់ព្រះអង្គ រាប់ថាមានដូចម្តេចកើត ក្នុងមនុស្សលោកនេះ ក្នុងកាលមុន ទូលព្រះបង្គំជាខ្ញុំ ធ្លាប់បានត្រេកអរដោយរូប សំឡេង រស ក្លិន ផស្សព្វ ជាទីសម្រើបចិត្ត ក្នុងទេវលោកមកហើយ ។

ភុត្តា ច មេ ភោគា តិទិវស្មឹ ទេវ, បរិវារិតោ អច្ឆរានំ គណេន;
តុវញ្ច ពាលំ បរនេយ្យំ វិទិត្វា, ន តាទិសេ រាជកុលេ វសេយ្យំ។

*បពិត្រសម្មតិទេព ឯភោគសម្បត្តិទាំងឡាយ ទូលព្រះបង្គំជាខ្ញុំបរិភោគហើយ ក្នុងទេវលោកឈ្មោះតាវត្តិង្ស ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលធ្លាប់មានពួកស្រីអប្សរចោមរោមហើយ ឯទូលព្រះបង្គំជាខ្ញុំ ស្គាល់ព្រះអង្គថា ជាមនុស្សពាល ដែលត្រូវតែគេដឹកនាំបាន (ទូន្មាន) ទូលព្រះបង្គំជាខ្ញុំមិនត្រូវនៅក្នុងរាជត្រកូលបែបព្រះអង្គទេ ។*

(ព្រះរាជាត្រាស់ថា)

**សចាហំ ពាលោ បរនេយ្យោ អស្មិ, ឯកាបរាធំ ខម បុត្ត មយ្ហំ;**
**បុនបិ ចេ ឯទិសកំ ករេយ្យ, យថាមតឹ សោមនស្ស ករោហិ។**

*នៃកូន បិតាជាមនុស្សពាល ដែលត្រូវតែគេដឹកនាំ ក៏សូមអ្នកអត់ទោសកំហុសម្តងដល់យើងចុះ ម្នាលសោមនស្ស បើទោសយ៉ាងនេះនឹងមានម្តងទៀត ចូរអ្នកធ្វើតាមមតិចុះ ។*

*ពាក្យថា **ជាបុគ្គលធ្លាប់មានពួកស្រីអប្សរចោមរោមហើយ** បានដល់ ជាបុគ្គលធ្លាប់មានពួកស្រីអប្សរបម្រើហើយ ។ បានឮមកថា **ជាតិស្សរញាណ**កើតមានដល់ព្រះមហាសត្វ ព្រោះហេតុនោះ ទើបលោកពោលយ៉ាងនេះ ។ ពាក្យថា **បែបព្រះអង្គទេ** សេចក្តីថា ព្រះពោធិសត្វពោលយ៉ាងនេះ ដើម្បីឲ្យព្រះរាជាដឹងថា បណ្ឌិតមិនគប្បីនៅក្នុងសម្នាក់ព្រះរាជាបែបព្រះអង្គ ទូលព្រះបង្គំបានជីវិតក្នុងថ្ងៃនេះដោយកម្លាំងបញ្ញារបស់ខ្លួន នឹងមិននៅក្នុងសម្នាក់ព្រះអង្គទេ ។ ពាក្យថា **ចូរអ្នកធ្វើតាមមតិចុះ** សេចក្តីថា ព្រះរាជាសូមខមាទោសបុត្រថា បើទោសបែបនេះមានម្តងទៀត អ្នកចូរធ្វើតាមអធ្យាស្រ័យចុះ ។*

*ព្រះមហាសត្វកាលនឹងឲ្យឱវាទព្រះរាជា ទើបពោល ៨ គាថាថា*

**អនិសម្ម កតំ កម្មំ, អនវត្ថាយ ចិន្តិតំ;**
**ភេសជ្ជស្សេវ វេភង្គោ, វិបាកោ ហោតិ បាបកោ។**

*ការងារដែលបុគ្គលមិនបានពិចារណាហើយធ្វើ គំនិតដែលបុគ្គលមិនកំណត់ហើយគិត រមែងមានផលអាក្រក់ ដូចជាការផ្សំថ្នាំខុសដូច្នោះ ។*

និសម្ម ច កតំ កម្មំ, សម្មាវត្វាយ ចិន្តិតំ;
ភេសជ្ជស្សេវ សម្បត្តិ, វិបាកោ ហោតិ ភទ្រកោ។

*ឯការងារ ដែលបុគ្គលពិចារណាហើយទើបធ្វើ គំនិតដែលបុគ្គលកំណត់ត្រឹមត្រូវហើយ ទើបគិត រមែងមានផលដ៏ចម្រើន ដូចជាការផ្សំថ្នាំត្រូវដូច្នោះឯង ។*

អលសោ គិហី កាមភោគី ន សាធុ, អសញ្ញតោ បព្ពជិតោ ន សាធុ;
រាជា ន សាធុ អនិសម្មការី, យោ បណ្ឌិតោ កោធនោ តំ ន សាធុ។

*គ្រហស្ថអ្នកបរិភោគកាមខ្ជិល មិនល្អ, អ្នកបួសមិនសង្រួម មិនល្អ, ព្រះរាជាអ្នកមិនពិចារណាហើយធ្វើ មិនល្អ, បណ្ឌិតដែលមានសេចក្ដីក្រោធ ការក្រោធនោះ ក៏មិនល្អឡើយ ។*

និសម្ម ខត្តិយោ កយិរា, នានិសម្ម ទិសម្បតិ;
និសម្មការិនោ រាជ, យសោ កិត្តិ ច វឌ្ឍតិ។

*បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រត្រូវពិចារណាហើយសឹមធ្វើ មិនត្រូវធ្វើទាំងមិនពិចារណាទេ បពិត្រព្រះរាជា ត្បិតថាយសនិងសេចក្ដីសរសើរ រមែងចម្រើន ដល់បុគ្គលអ្នកពិចារណាហើយទើបធ្វើ ។*

និសម្ម ទណ្ឌំ បណយេយ្យ ឥស្សរោ, វេគា កតំ តប្បតិ ភូមិបាល;
សម្មាបណីធី ច នរស្ស អត្ថា, អនានុតប្បា តេ ភវន្តិ បច្ឆា។

បពិត្រព្រះភូមិបាល បុគ្គលជាធំ ត្រូវតែពិចារណាហើយសឹមដាក់អាជ្ញា ការដែលបុគ្គលធ្វើ ដោយរួសរាន់ រមែងក្តៅក្រហាយ ម្យ៉ាងទៀត ប្រយោជន៍ទាំងឡាយដែលនរជនផ្គងឡើងត្រឹមត្រូវនោះ រមែងជាប្រយោជន៍ មិនក្តៅក្រហាយខាងក្រោយ ។

អជានុតប្បានិ ហិ យេ ករោន្តិ, វិភជ្ជ កម្មាយតនានិ លោកេ;
វិញ្ញុប្បសត្ថានិ សុខុទ្រយានិ, ភវន្តិ ពុទ្ធានុមតានិ តានិ។

ជនទាំងឡាយ បែងចែកហើយទើបធ្វើការងារទាំងឡាយ ដែលមិនមានសេចក្តីក្តៅក្រហាយក្នុងលោក ការងារទាំងនោះ ជាអំពើដែលអ្នកប្រាជ្ញសរសើរហើយថា មានសេចក្តីសុខជាកម្រៃ ជាអំពើដែលអ្នកប្រាជ្ញចុះអនុមតិហើយ ។

អាគច្ឆុំ ទោវារិកា ខគ្គពន្ធា, កាសាវិយា ហន្តុ មមំ ជនិន្ទ;
មាតុញ្ច អង្គស្មិមហំ និសិន្នោ, អាកឌ្ឍិតោ សហសា តេហិ ទេវ។

បពិត្រព្រះអង្គ ជាធំជាងជន ពួកឆ្មាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាត មកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ អង្គុយលើព្រះឧរូនៃមាតា ត្រូវពួកទូតទាំងនោះ ទងទាញមកដោយរហ័ស ។

កដុកញ្ហិ សម្ពាធំ សុគាឡ្ហំ បត្តោ, មធុរម្បិ យំ ជីវិតំ លទ្ធ រាជ;
កិច្ឆេនហំ អជ្ជ វធា បមុត្តោ, បព្ពជ្ជមេវាភិមនោហមស្មិ។

ទូលព្រះបង្គំជាខ្ញុំ បានដល់នូវមរណភ័យ ក៏ក្តៅក្រហាយយ៉ាងចង្អៀត លំបាកក្រៃពេក បពិត្រព្រះរាជា ជីវិតដែលជាទីស្រឡាញ់ដូចមធុរស ទូលព្រះបង្គំជាខ្ញុំបានហើយ ថ្ងៃនេះទូលព្រះបង្គំជាខ្ញុំ បានរួចចាកការសម្លាប់ដោយលំបាក ទូលព្រះបង្គំជាខ្ញុំ មានចិត្តឱនឆ្ពោះទៅក្នុងបព្វជ្ជាតែម្យ៉ាង ។

*ព្រះរាជាស្តាប់ធម៌ដែលព្រះមហាសត្វសម្តែងយ៉ាងនេះហើយ ទ្រង់ហៅព្រះទេវី ត្រាស់គាថាថា*

**បុត្តោ តវាយំ តរុណោ សុធម្មេ, អនុកម្បកោ សោមនស្សោ កុមារោ;**
**តំ យាចមានោ ន លភាមិ ស្វជ្ជ, អរហាសិ នំ យាចិតវេ តុវម្បិ។**

*ម្នាលសុធម្មាទេវី សោមនស្សកុមារជាបុត្ររបស់នាងនេះ នៅក្មេង ជាអ្នកអនុគ្រោះ ថ្ងៃនេះ ខ្ញុំអង្វរករកុមារនោះពុំបានសោះ ក្រែងតែនាងទើបអង្វរករនូវកុមារនោះបាន ។*

*ព្រះនាងសុធម្មាកាលនឹងបញ្ជូនព្រះរាជបុត្រឲ្យបួស ទើបពោលគាថាថា*

**រមស្សុ ភិក្ខាចរិយាយ បុត្ត, និសម្ម ធម្មេសុ បរិព្ពជស្សុ;**
**សព្ពេសុ ភូតេសុ និធាយ ទណ្ឌំ, អនិន្ទិតោ ព្រហ្មមុបេតិ ឋានំ។**

*ហៃបា ចូរអ្នកត្រេកអរក្នុងភិក្ខាចរិយវត្តចុះ ចូរអ្នកពិចារណាធម៌ទាំងឡាយហើយ បួសចុះ អ្នកចូរទម្លាក់ចោលនូវអាជ្ញាក្នុងពួកសត្វទាំងអស់ចេញ មិនមានអ្នកណានិន្ទាបាន ហើយចូរទៅកាន់ឋានព្រហ្មលោកចុះ ។*

*ពាក្យថា **ចូរអ្នកពិចារណាធម៌** សេចក្តីថា អ្នកកាលបួស ចូរពិចារណា ហើយលះការបួសរបស់បុគ្គលមិច្ឆាទដ្ឋិ ចូរបួសតាមបព្វជ្ជាដែលដឹកនាំសត្វឲ្យរួចផុតចាកទុក្ខ ដែលប្រកបដោយសម្មាទិដ្ឋិចុះ ។*

*លំដាប់នោះ ព្រះរាជាពោលគាថាថា*

**អច្ឆេររូបំ វត យាទិសញ្ច, ទុក្ខិតំ មំ ទុក្ខាបយសេ សុធម្មេ;**
**យាចស្សុ បុត្តំ ឥតិ វុច្ចមានា, ភិយ្យោវ ឧស្សាហយសេ កុមារំ។**

*ម្នាលនាងសុជម្មា នាងនិយាយពាក្យណា (ពាក្យនោះ) ជាអស្ចារ្យក្រៃពេក នាងឈ្មោះថាញ៉ាំងខ្ញុំដែលដល់នូវសេចក្តីទុក្ខ ឲ្យរឹតតែបានទុក្ខឡើង កាលខ្ញុំនិយាយថា ចូរនាងអង្វរករបុត្រ នាងបែរជាញ៉ាំងកុមារឲ្យប្រឹងប្រែងវិញ ។*

*ព្រះនាងទេវីក៏ពោលគាថាម្តងទៀតថា*

**យេ វិប្បមុត្តា អនវជ្ជភោគិនោ, បរិនិព្ពុតា លោកមិមំ ចរន្តិ;**
**តមរិយមគ្គំ បដិបជ្ជមានំ, ន ឧស្សហេ វារយិតុំ កុមារំ។**

*ព្រះអរិយៈទាំងឡាយណា រួចស្រឡះហើយ (ចាករាគាទិក្កិលេស) ជាអ្នកបរិភោគនូវភោជនមិនមានទោស រំលត់ហើយ តែងត្រេចទៅកាន់លោកនេះ ខ្ញុំម្ចាស់មិនអាចហាមឃាត់ព្រះរាជកុមារ ដែលកំពុងដើរទៅកាន់ផ្លូវរបស់ព្រះអរិយៈនោះបានទេ ។*

*ពាក្យថា* **រំលត់ហើយ** *បានដល់ រលត់ដោយកិលេសបរិនិព្វាន ។*

*ព្រះរាជាស្តាប់ព្រះនាងហើយ ក៏ត្រាស់***ឱសានគាថា***ថា*

**អទ្ធា ហវេ សេវិតព្ពា សបញ្ញា, ពហុស្សុតា យេ ពហុឋានចិន្តិនោ;**
**យេសាយំ សុត្វាន សុភាសិតានិ, អប្បោស្សុក្កា វីតសោកា សុជម្មា។**

*ជនទាំងឡាយណា ប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ នាងសុជម្មាទេវីនេះ ជាស្ត្រីមានសេចក្តីខ្វល់ខ្វាយតិច ប្រាសចាកសេចក្តីសោក ព្រោះបានស្តាប់ពាក្យសុភាសិតទាំងឡាយនៃពួកជនណា ជនទាំងនោះ គួរអ្នកផងគប់រកដោយពិត ។*

*ពិតមែនហើយ ព្រះនាងសុជម្មាទេវីនោះ បានស្តាប់សុភាសិត របស់សោមនស្សកុមារហើយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ព្រះរាជាត្រាស់សំដៅយកព្រះរាជបុត្រនោះឯង ។*

*ព្រះមហាសត្វថ្វាយបង្គំមាតាបិតា ហើយទូលថា បើទោសរបស់ទូលព្រះបង្គំមាន សូមលោកអត់ទោសដល់ខ្ញុំផង ដូច្នេះហើយ ព្រះអង្គធ្វើអញ្ជលីដល់មហាជន មានមុខឆ្ពោះទៅរកព្រៃហិមពាន្តយាងទៅ កាលពួកមនុស្សអ្នកជូនដំណើរត្រឡប់ហើយ ត្រូវពួកទេវតាមកដោយភេទជាមនុស្សនាំព្រះអង្គទៅ កន្លងផុតជួរភ្នំ ៧ នាំទៅកាន់ព្រៃហិមពាន្ត ហើយបួសជាឥសីក្នុងបណ្ណសាលាដែលវិស្សុកម្មទេពនិម្មិត ។ ពួកទេវតានៅបម្រើព្រះរាជកុមារ ក្នុងទីនោះដោយភេទជាអ្នកបម្រើរាជត្រកូល រហូតដល់ព្រះរាជកុមារមានព្រះជន្ម ១៦ ឆ្នាំ ។ មហាជននាំគ្នាវាយជដិលកោង ឲ្យអស់ជីវិត ។ ចំណែកព្រះមហាសត្វញ៉ាំងឈាននិងអភិញ្ញាឲ្យកើតឡើង ក៏ជាអ្នកចូលទៅកាន់ព្រហ្មលោក ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមសម្លាប់តថាគតយ៉ាងនេះដែរ ហើយទ្រង់ប្រជុំជាតកថា*

**តទា កុហកោ ទេវទត្តោ អហោសិ** *កុហកតាបស បានមកជាទេវទត្ត*

**មាតា មហាមាយា** *ព្រះមាតាបានមកជាព្រះនាងមហាមាយា*

**មហារក្ខិតោ សារិបុត្តោ** *មហារក្ខិតតាបសបានមកជាសារីបុត្រ*

**សោមនស្សកុមារោ បន អហមេវ អហោសឹ** *ចំណែកសោមនស្សកុមារ គឺតថាគតនេះឯង ។*

*សោមនស្សជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក វីសតិនិបាត សោមនស្សជាតក បិដកលេខ ៦០ ទំព័រ ១០៨)*

*ថ្ងៃ សៅរ៍ ១៣ កើត ខែភទ្របទ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២២ ខែ កញ្ញា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*